# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៩-១០-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន នាយនគរបាល និង មន្ត្រីរាជការនៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ចំនួន ៦០ រូប ៧៧៧៩

០៩-១០-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១៧ ស្តីពី ការតែងតាំងជាទីប្រឹក្សារាជរដ្ឋាភិបាល ចំនួន ០៥ រូប ៧៧៨១

០៩-១០-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១៨ ស្តីពី ការតែងតាំងលោកជំទាវ **តាន់ គីមហ្វួត** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ ៧៧៨២

០៩-១០-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១០១២/៩១៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោកអនុសេនីយ៍ឯក **តា សំអាត** ៧៧៨៣

១០-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩២០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូនមន្ត្រីរាជការ ចំនួន ០៩ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ៧៧៨៤

១០-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩២៣ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ម៉ៅ ស្រ៊ុន** ពីរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ៧៧៨៦

១០-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩២៤ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ជូនចំពោះ សពលោក **ប៉ែន សេង** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៧៧៨៧

១០-១០-២០១២-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩២៥ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ៧៧៨៨

១៣-១០-២០១៤-ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៣៥ ស្តីពី ការបញ្ចប់មុខតំណែង ឧត្តមសេនីយ៍ឯក **ឡើន សុខណ្ណ** ពីទីប្រឹក្សាក្រសួងមហាផ្ទៃ ដកហូតឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក និង លុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៧៧៩៣

១៦-១០-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១០១២/៩៤៦ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ ៧៧៩៤

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

*-អនុក្រឹត្យលេខ ១៧២ អនក្រ.បក មិនទាន់បានទទួល*

១០-១០-២០១២ -អនុក្រឹត្យលេខ ១៧៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៧៧៩៧

១១-១០-២០១២ -អនុក្រឹត្យលេខ ១៧៤ អនក្រ.បក ស្តីពី ការគ្រប់គ្រងលើការនាំចូលត្បូងពេជ្រមិនទាន់កែច្នៃ និង ការនាំចេញ ត្បូងពេជ្រដែលបានកែច្នៃរួច ក្នុងការអនុវត្តន៍គម្រោងចេញវិញ្ញាបនបត្រគីមប័រលី ៧៧៩៩

១១-១០-២០១២ -អនុក្រឹត្យលេខ ១៧៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៧៨០៣

១១-១០-២០១២ -អនុក្រឹត្យលេខ ១៧៦ អនក្រ.បក ស្តីពី ការធ្វើអនុបយោគផ្ទៃដីទំហំ ៩.៣៧២,៧៤ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ៧៨០៥

១១-១០-២០១២ -អនុក្រឹត្យលេខ ១៧៧ អនក្រ.បក ស្តីពី ការធ្វើអនុបយោគផ្ទៃដីទំហំ ៩.៣១២,៣៩ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ៧៨០៧

០២-១០-២០១២ -អនុក្រឹត្យលេខ **១៣៨៣** ដល់អនុក្រឹត្យលេខ **១៤៤១** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៨០៩

### ២-សេចក្តីសម្រេច

០៩-១០-២០១២ -សេចក្តីសម្រេចលេខ ៤០ សសរ ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៧៨៦៨

១២-១០-២០១២ -សេចក្តីសម្រេចលេខ ៤១ សសរ ស្តីពី ការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍លើវិស័យមីន ៧៨៦៩

## III-ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៨៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេចស៊ីអិម អ៊ីមផត អិចផត** ៧៨៧២

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៨៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **5 ស៊ីប៊ីខេ អិមឌីស៊ី** ៧៨៧៤

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៩១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស 2 អេនជីនារីង & ឌីហ្សាញ** ៧៨៧៦

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៩២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូសារ៉ាត ហ៊ែលធ្លឺរី** ៧៨៧៨

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៩៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេនរីច ផ្លេនថេសិន តិធីអ៊ី អិលធីឌី** ៧៨៨០

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៩៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រីហ្វេសិនណល ហ្គោល អ៊ិនវេសមេន** ៧៨៨២

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៩៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ៃគ្រីត (ខេមបូឌា) ខូ អិលធីឌី** ៧៨៨៣

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៣៩៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម.អ៊ី.អ៊ី.ថេក គ្រុប** ៧៨៨៥

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៤១៧ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **បៃធី អ៊ិនធើណេសិនណល** ៧៨៨៧

១៧-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៤៣០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ឥណ្ឌូឆាយណា អេស៊ាន គ្រុប លីមីធីត** ៧៨៨៩

២១-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៤៣៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន ស្ត្រែត** ៧៨៩១

២១-៦-២០១១ -លិខិតបញ្ជាក់លេខ ៣៤៣៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន ចាស្ទីន** ៧៨៩៣

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហាន នាយនគរបាល និងមន្ត្រីរាជការនៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
ចំនួន៦០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ កន្លងមក

នូវ

### ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ឯក | សេង | ភ័ន់ធី | អត្តលេខ ០០០៥៩០ | ៥-ឧត្តមសេនីយ៍ទោ | ភ៉ | សារ៉ែន | អត្តលេខ ០១៧៦ |
| ២-ឧត្តមនាវីទោ | យុន | បូរិន្ទ | អត្តលេខ ០០២៥២៩ | ៦-ឧត្តមសេនីយ៍ត្រី | សូ | មៅ | អត្តលេខ ០០១៣៣៣ |
| ៣-ឧត្តមនាវីទោ | យិន | ច័ន្ទឌី | អត្តលេខ ០០៤៩៥១ | ៧-ឧត្តមសេនីយ៍ត្រី | ឈៀង | ភីរុណ | អត្តលេខ ០០៣៨៧២ |
| ៤-ឧត្តមនាវីទោ | វណ្ណ | ប៊ុនលៀង | អត្តលេខ ០០១១០៤ | ៨-វរសេនីយ៍ឯក | រស់ | សុខសំបូរ | អត្តលេខ ០៥៨៨៩ |

### ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | | |
|---|---|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | គេង | សួន | អត្តលេខ ០៧២៦២ | ២-ឯកឧត្តម | ពុំ | សុជា |

### គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ឯក | សួន | សំណាង | អត្តលេខ ០០០២០៦ | ៤-ឧត្តមសេនីយ៍ទោ | សៅ | ច័ន្ទតារា | អត្តលេខ ០០១៣៨៦ |
| ២-ឧត្តមនាវីទោ | គ្រួច | គឹមថុន | អត្តលេខ ០០២៥២៨ | ៥-ឧត្តមនាវីត្រី | ម៉ោញ | ឈុនឌី | អត្តលេខ ០០២៨១៨ |
| ៣-ឧត្តមនាវីទោ | ទៀ | សុខា | អត្តលេខ ០០៤២០៩ | | | | |

### ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | ភ៉ន់ | សុផាន់ណា | អត្តលេខ ០១៩៣៣០ | ៥-ឧត្តមនាវីត្រី | ហែម | សុខេង | អត្តលេខ ០៣១០៥២ |
| ២-ឧត្តមនាវីត្រី | នង | វណ្ណថា | អត្តលេខ ០១០២៩៦ | ៦-ឧត្តមសេនីយ៍ត្រី | អ៊ឹង | វណ្ណនី | អត្តលេខ ០០១៣៦២ |
| ៣-ឧត្តមនាវីត្រី | ឈុំ | សារុធ | អត្តលេខ ០១០៣០៣ | ៧-ឧត្តមសេនីយ៍ត្រី | រស់ | សុជាត | អត្តលេខ ០០១៣៨៨ |
| ៤-ឧត្តមនាវីត្រី | សៅ | ចាន់ | អត្តលេខ ០១០៣១៦ | | | | |

### ង-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

| | | | | |
|---|---|---|---|---|
| ១-លោក | ង៉ែត | ឆៃលី | ២-លោក សំ ទុយ | ហៅ ណាត |

### ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | យិន | សុធី | អត្តលេខ ០២៥៦៧១ | ៣- វរនាវីឯក | យ៉ាំង | គីហួត | អត្តលេខ ០១៥០៣៣ |
| ២-ឧត្តមសេនីយ៍ឯក | គី | មុនី | អត្តលេខ ០០១៤៦៨ | ៤- វរនាវីឯក | ទន់ | សារុន | អត្តលេខ ០១៥១២៦ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥-វរនាវីឯក | គង់ | ឈួន | អត្តលេខ ០១៥០៥១ | ៧-វរនាវីទោ | សេង | វាសនា | អត្តលេខ ០៣១១២៨ |
| ៦-វរនាវីទោ | ជឹម | សុវត្ថិ | អត្តលេខ ០៥៦០៥១ | | | | |

## ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- វរនាវីឯក | ឈុន | ប៉ាក់ | អត្តលេខ ០១០២៨២ | ៥-វរនាវីទោ | ឡាំ | សំបូរ | អត្តលេខ ០១៥០៥៧ |
| ២- វរនាវីឯក | ហោ | សេងលីម | អត្តលេខ ០០២៥១៩ | ៦-វរនាវីទោ | ថៃ | ចន្ថា | អត្តលេខ ០៣០៩៧៩ |
| ៣- វរសេនីយ៍ទោ | ហេង | សុវត្ថិ | អត្តលេខ ០១៣២៦ | ៧-វរនាវីត្រី | ឡឹក | សាថន | អត្តលេខ ០១៩២២០ |
| ៤- វរសេនីយ៍ទោ | ហេង | រ៉ាវី | អត្តលេខ ០២៧៤៨២ | | | | |

## ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាថ្នាក់ អស្សឫទ្ធិ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- វរសេនីយ៍ឯក | សោម | សាក់ក្រវ៉ាន់ | អត្តលេខ ០១៣៣៤ | ១២-វរនាវីទោ | វ៉ែន | ឈិន | អត្តលេខ ០៤២៧៦៨ |
| ២- វរនាវីឯក | កាន់ | កៅ | អត្តលេខ ០០១៦៦៨ | ១៣-វរនាវីទោ | កែវ | ថុល | អត្តលេខ ០៣១០៥៨ |
| ៣- វរសេនីយ៍ឯក | អ៊ឹង | ផាន | អត្តលេខ ១៧៩៤៣៤ | ១៤-វរនាវីទោ | រស់ | សារីម | អត្តលេខ ០១៥០៣៩ |
| ៤- វរនាវីឯក | ជឹម | សុវណ្ណ | អត្តលេខ ០១៥១៥៤ | ១៥-វរសេនីយ៍ទោ | ស្រែ | មៅ | អត្តលេខ ០៤៧៩៥៣ |
| ៥-វរនាវីឯក | នង | ខេមរង្សី | អត្តលេខ ០១៥១០៤ | ១៦-វរសេនីយ៍ទោ | យ៉ន | ស៊ុនហួរ | អត្តលេខ ០០៨៧៥២ |
| ៦-វរនាវីឯក | មៅ | សាមឿន | អត្តលេខ ០១២២៩៦ | ១៧-វរនាវីទោ | វ៉ាត | សារិទ្ធ | អត្តលេខ ០៤២៨៤៥ |
| ៧-វរនាវីទោ | ទេព | ម៉ារ៉ាវង្ស | អត្តលេខ ០១៥០៧២ | ១៨-វរនាវីទោ | ហាម | ពុទ្ធារ៉ា | អត្តលេខ ០៥៥៥៤១ |
| ៨-វរនាវីទោ | ព្រំ | សំអឿន | អត្តលេខ ០៣០៩២០ | ១៩-វរនាវីទោ | សេក | គន្ធី | អត្តលេខ ០១៤៩៩១ |
| ៩- វរសេនីយ៍ទោ | សៅ | សុខវិន្ថា | អត្តលេខ ០២១២៩៩ | ២០-វរនាវីត្រី | ស៊ូ | ចន្ទ្រាបុត្រ | អត្តលេខ ០៤៨៤៩៥ |
| ១០-វរនាវីទោ | ជ័យ | ចាន់ | អត្តលេខ ០៣១០៩១ | ២១-វរនាវីត្រី | ហ៊ែល | ស៊ីថាន់ | អត្តលេខ ០៦២៩៣៦ |
| ១១-វរនាវីទោ | នួន | ស៊ីវាសនា | អត្តលេខ ០៤២៧៤៧ | ២២-អនុនាវីទោ | ស៊ុំ | សម្បត្តិ | អត្តលេខ ០៥៥៥៤៣ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.១២១០.៩២៥

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២

លេខៈ ៨៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១២

អគ្គលេខា[illegible]រងទីស្ដី[illegible]រដ្ឋាភិបាល

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងជាទីប្រឹក្សារាជរដ្ឋាភិបាល ចំនួន ០៥រូប :

| | | |
|---|---|---|
| ១-ឯកឧត្តម | **ឆៅ ម៉ិនស៊្រី** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២-លោកជំទាវ | **មុំ ផល្លា** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៣-ឯកឧត្តម | **ទឹម លាងឈឿន** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៤-ឯកឧត្តម | **នួន ហាម** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៥-ឯកឧត្តម | **ម៉ៅល គឹមមន** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រសោ.១២១០.៩១៧

លេខៈ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល
សុម សុខា

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២*

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោកជំទាវ **តាន់ គីមហួត** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរសា.១២១០.៩២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២

លេខៈ ៨៤៣ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩១៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

លោកអនុសេនីយ៍ឯក ភា សំអាត

ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា
ក្នុងវិស័យព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ក្នុងខេត្តស្វាយរៀង

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible].១២.១០.៩២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២

លេខៈ ៨៨៦ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០១២
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ស្វាយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០៩ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ៖

| **រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** | | | | |
|---|---|---|---|---|
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
| [illegible] | កែវ ស៊ីថន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

LE MINISTRE DU PALAIS ROYAL ROYAUME DU CAMBODGE
ព្រះបរមរាជវាំង

| ក្រសួងទេសចរណ៍ | | | | |
|---|---|---|---|---|
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
| ១ | ប៉ាក់ សុខុម | ប | ពីវរមន្ត្រី ថ្នាក់លេខ ២ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ២ | ឌួង ធីរៈ | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៣ | សម មុន្នីកា | ស | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៤ | ហោ សារុន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៥ | និត ចន្ថា | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៦ | សៀង គឹមហាន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ក្រសួងផែនការ | | | | |
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
| ១ | ជឹម លាង | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ក្រសួងពាណិជ្ជកម្ម | | | | |
| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង |
| ១ | អ៊ា រុតសាន | ប | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣:** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.១២១០.៩៧០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២*

លេខ:៨៨៥ ច.ល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ១០ ឆ្នាំ២០១២**

**អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩២៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បញ្ចប់មុខតំណែងឯកឧត្តម **ម៉ៅ ស្រ៊ុន** ពីរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២** : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៥៥២ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១២
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

៣៦៣.១២១០.៩២៣

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩២៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ជាកិច្ចបច្ឆាមរណៈ**

ជូនចំពោះ

សពលោក **ប៉ែន សេង**

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១២១០.៩៣៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២

លេខៈ ៨៧០ ច.ល
**ដើម្បីថតចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៧៥

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជីវសុវត្ថិភាព
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងដែលសរសេរជាអក្សរកាត់ថា **ក.ជ.អ.ប.** ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង សុខភាពសាធារណៈ គុណភាពបរិស្ថាន ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងរក្សាអត្តសញ្ញាណវប្បធម៌ជាតិ ដោយផ្អែកលើបង្គោលគ្រឹះ៤គឺ សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមាសភាពរបស់ ក.ជ.អ.ប.

**មាត្រា ២.-**

**ក.ជ.អ.ប.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- រដ្ឋលេខាធិការក្រសួងកិច្ចការនារី១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប សមាជិក
- អគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក
- អគ្គលេខាធិការ **ក.ជ.អ.ប.** សមាជិក។

សមាសភាពជាក់ស្តែងរបស់ **ក.ជ.អ.ប.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ជ.អ.ប.

**មាត្រា ៣.-**

**ក.ជ.អ.ប.** ជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលនិងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍បៃតង
- ជំរុញនិងលើកទឹកចិត្តឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធនៅក្នុងការរៀបចំនិងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍បៃតង
- សម្របសម្រួលនិងសហការធ្វើសកម្មភាពនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតង ជាមួយនឹងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនដែលមានការពាក់ព័ន្ធ
- បញ្ជ្រាបគោលការណ៍អភិវឌ្ឍន៍បៃតង រួមមាន ការងារបរិស្ថានបៃតងនិងធនធានធម្មជាតិ ការងារធនធានទឹកនិងអនាម័យ ការងារសន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ ព្រមទាំងការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ការងារសេដ្ឋកិច្ច ការងារវិនិយោគ ការងារគមនាគមន៍ ការងារឧស្សាហកម្មនិងថាមពលបៃតង ការងារទេសចរណ៍ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

- អភិវឌ្ឍធនធានមនុស្សដើម្បីគាំទ្រដល់ការអភិវឌ្ឍបៃតង
- ជំរុញលើកទឹកចិត្តនិងបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍បៃតងដោយផ្តោតលើយេនឌ័រនិងជនជាតិដើមភាគតិច
- ផ្លាស់ប្តូរនិងទទួលបច្ចេកវិទ្យាបៃតងនៅក្នុងក្របខ័ណ្ឌតំបន់និងសកលលោក សំដៅដល់ការលើកស្ទួយសេដ្ឋកិច្ចបៃតងឲ្យមានតុល្យភាពទៅនឹងចីរភាពបរិស្ថាននិងសង្គម
- ចូលរួមកិច្ចប្រជុំរាល់វេទិកាជាតិនិងអន្តរជាតិដែលទាក់ទងនឹងការអភិវឌ្ឍបៃតង
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍បៃតង អនុសញ្ញា កិច្ចព្រមព្រៀង និងពិធីសារអន្តរជាតិនានា ដែលកាតីកម្ពុជាបានចូលជាសមាជិក
- លើកកម្ពស់និងពង្រឹងសមត្ថភាពដល់ស្ថាប័នអនុវត្តនិងស្ថាប័នពាក់ព័ន្ធ ស្របតាមគោលនយោបាយអភិវឌ្ឍន៍បៃតង
- បញ្ជ្រាបការអភិវឌ្ឍបៃតងទៅក្នុងវិស័យអប់រំ
- ជំរុញនិងលើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយអំពីការអភិវឌ្ឍបៃតងដល់ផ្នែកសាធារណៈ ឯកជន និងសង្គមស៊ីវិល
- ពិនិត្យនិងផ្តល់យោបល់លើការសិក្សាស្រាវជ្រាវទាក់ទងនឹងការអភិវឌ្ឍបៃតង
- តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងកម្មវិធីអភិវឌ្ឍន៍បៃតង
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ជ.អ.ប.

**មាត្រា ៤.-**

**ក.ជ.អ.ប.** ត្រូវប្រជុំយ៉ាងតិច២ដងក្នុង១ឆ្នាំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ ប្រធាន **ក.ជ.អ.ប.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះយោបល់និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានឬអនុប្រធានប្រចាំការ អាចដឹកនាំការប្រជុំជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន។

**មាត្រា ៥.-**

**ក.ជ.អ.ប.** អាចមានទីប្រឹក្សាបច្ចេកទេសនិងអ្នកជំនាញការជាតិឬអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

**មាត្រា ៦.-**

**ក.ជ.អ.ប.** ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ហើយដែលមានទីស្នាក់ការនៅក្រសួងបរិស្ថាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន **ក.ជ.អ.ប.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបអមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **ក.ជ.អ.ប.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៨.-**

**ក.ជ.អ.ប.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ៩.-**

**ក.ជ.អ.ប.** មានថវិកាដោយឡែករបស់ខ្លួនដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងបរិស្ថាន។

**ក.ជ.អ.ប.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី **១០** ខែ **តុលា** ឆ្នាំ ២០១២

នស.រកត.១០១២.៩៣៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ ៩៧១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០១២

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៣៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងឧត្តមសេនីយ៍ឯក **ឡឿន សុទណ្ណ** អត្តលេខ ០២៦៦៩ ពីទីប្រឹក្សាក្រសួងមហាផ្ទៃ ដកហូតឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯក និងលប់ឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៧៧៣.១២១០.៩៤៥

*ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២*

លេខ: ៥៩២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ តុលា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៤៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា នីតិកាលទី៣ នាសម័យប្រជុំដំបូងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១២
- បានទ្រង់យល់លទ្ធផលបោះឆ្នោតជាកញ្ចប់របស់រដ្ឋសភាកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៦៥ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៤ ស្តីពីការតែងតាំងសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ដូចមានសមាសភាពខាងក្រោម៖

| | | | |
|---|---|---|---|
| ១. សម្តេចអគ្គមហាធម្មពោធិសាល | ជា ស៊ីម | ប្រធានព្រឹទ្ធសភា | ប្រធាន |
| ២. សម្តេចអគ្គមហាពញាចក្រី | ហេង សំរិន | ប្រធានរដ្ឋសភា | អនុប្រធាន |
| ៣. សម្តេចអគ្គមហាសេនាបតីតេជោ | ហ៊ុន សែន | នាយករដ្ឋមន្ត្រី | អនុប្រធានប្រចាំការ |
| ៤. សម្តេចចៅហ្វាវាំង | គង់ សំអុល | ឧបនាយករដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. ឯកឧត្តម | ស ខេង | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៦. ឯកឧត្តម | សុខ អាន | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៧. ឯកឧត្តម | ទៀ បាញ់ | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៨. ឯកឧត្តម | ហោ ណាំហុង | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៩. លោកជំទាវ | ម៉ែន សំអន | ឧបនាយករដ្ឋមន្ត្រីប្រចាំការ | អនុប្រធាន |
| ១០.ឯកឧត្តម | ប៊ិន ឈិន | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១១.ឯកឧត្តម | ញឹក ប៊ុនឆៃ | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១២.ឯកឧត្តម | គាត ឈន់ | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១៣.ឯកឧត្តម | យឹម ឆៃលី | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១៤.ឯកឧត្តម | កែ គឹមយ៉ាន | ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១៥.ឯកឧត្តម | អ៊ឹម ឈុនលឹម | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦.ឯកឧត្តម | វ៉ិម យ៉ុនទៀង | ទេសរដ្ឋមន្ត្រី | សមាជិក |
| ១៧.ឯកឧត្តម | ខៀវ កាញារីទ្ធ | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ១៨.ឯកឧត្តម | ហ៊ឹម ឆែម | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៩.ឯកឧត្តម | មិន ឃិន | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | សមាជិក |
| ២០.ឯកឧត្តម | ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ២១.ឯកឧត្តម | អ៊ឹម សិទ្ធី | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២២.ឯកឧត្តម | នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២៣.ឯកឧត្តម | សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៤.ឯកឧត្តម | ម៉ៅ ហាវណ្ណាល់ | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ២៥.ឯកឧត្តម | ស្វាយ ស៊ីថា | ប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស | សមាជិក |
| ២៦.ឯកឧត្តម | កែប ជុតិមា | អភិបាលរាជធានីភ្នំពេញ | សមាជិក |
| ២៧.ឯកឧត្តម | ស្បោង សារ៉ាត | អភិបាលខេត្តព្រះសីហនុ | សមាជិក |
| ២៨.ឯកឧត្តម | កែន សត្ថា | អភិបាលខេត្តកែប | សមាជិក |
| ២៩.ឯកឧត្តម | អ៊ី ឈាន | អភិបាលខេត្តប៉ៃលិន | សមាជិក |
| ៣០.ឯកឧត្តម | ឈុន ស៊ីរុន | អភិបាលខេត្តកណ្ដាល | សមាជិក |
| ៣១.ឯកឧត្តម | ហាស់ សារ៉េត | អភិបាលខេត្តព្រៃវែង | សមាជិក |
| ៣២.ឯកឧត្តម | ជៀង អំ | អភិបាលខេត្តស្វាយរៀង | សមាជិក |
| ៣៣.ឯកឧត្តម | ហ៊ុន ណេង | អភិបាលខេត្តកំពង់ចាម | សមាជិក |
| ៣៤.ឯកឧត្តម | ស្រី បេន | អភិបាលខេត្តតាកែវ | សមាជិក |
| ៣៥.ឯកឧត្តម | ខួយ ឃុនហួរ | អភិបាលខេត្តកំពត | សមាជិក |
| ៣៦.ឯកឧត្តម | ប៊ុន លើត | អភិបាលខេត្តកោះកុង | សមាជិក |
| ៣៧.ឯកឧត្តម | កង ហ៊ាង | អភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ៣៨.ឯកឧត្តម | ឈុន ឈន់ | អភិបាលខេត្តកំពង់ធំ | សមាជិក |
| ៣៩.ឯកឧត្តម | ទូច ម៉ារីម | អភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ៤០.ឯកឧត្តម | ខូយ សុខា | អភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| ៤១.ឯកឧត្តម | ប្រាជ ចន្ទ | អភិបាលខេត្តបាត់ដំបង | សមាជិក |
| ៤២.ឯកឧត្តម | អ៊ុង អឿន | អភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |

| | | | |
|---|---|---|---|
| ៤៣.ឯកឧត្តម | ប៉ិច សុខិន | អភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| ៤៤.ឯកឧត្តម | ស៊ូ ភិរិន្ទ | អភិបាលខេត្តសៀមរាប | សមាជិក |
| ៤៥.ឯកឧត្តម | អ៊ុំ ម៉ារ៉ា | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ៤៦.ឯកឧត្តម | ឡូយ សុផាត | អភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| ៤៧.ឯកឧត្តម | ប៉ាវ ហមផាន | អភិបាលខេត្តរតនគីរី | សមាជិក |
| ៤៨.ឯកឧត្តម | ចាន់ យឿន | អភិបាលខេត្តមណ្ឌលគីរី | សមាជិក |
| ៤៩.ឯកឧត្តម | សរ ចំរុង | អភិបាលខេត្តក្រចេះ | សមាជិក |

**មាត្រា ២.-**

គណៈកម្មាធិការនេះមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំព្រះរាជពិធីបុណ្យព្រះបរមសពឱ្យមានដំណើរការល្អ ឧត្តុង្គឧត្តមសក្តិសមនឹងព្រះគោរមងារ របស់ព្រះអង្គជាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ
- សម្របសម្រួលការងាររៀបចំព្រះរាជពិធីបុណ្យព្រះបរមសពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំព្រះរាជពិធីទទួល និងដង្ហែព្រះបរមសព
- រៀបចំតម្កល់ព្រះបរមសព គោរពព្រះវិញ្ញាណក្ខន្ធ និងកិច្ចការពាក់ព័ន្ធផ្សេងៗ
- រៀបចំព្រះរាជពិធីបូជាព្រះបរមសពឱ្យមានដំណើរការល្អ និងឧត្តុង្គឧត្តម

**មាត្រា ៣.-**

គណៈកម្មាធិការនេះអាចបង្កើតអនុគណៈកម្មការដើម្បីបំពេញការងារ តាមការចាំបាច់។

**មាត្រា ៤.-**

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១០១២.៩៨៦

ធ្វើនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១២

លេខ: ៨៩១ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤. ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៤ អនក្រ.បក, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន២ ៨៨០ ០៤២ ០០០រៀល(ពីរពាន់ប្រាំបីរយប៉ែតសិបលានសែសិបពីរពាន់រៀលគត់) ពីជំពូក៦០(ការទិញ) ចំនួន៩៣៩ ៩៤២ ០០០រៀល(ប្រាំបួនរយសាមសិបប្រាំបួនលានប្រាំបួនរយសែសិបពីរពាន់រៀលគត់) ជំពូក៦១(សេវាខាងក្រៅ) ចំនួន១ ៧៣០ ៧០០ ០០០រៀល(មួយពាន់ប្រាំពីររយសាមសិបលានប្រាំពីររយពាន់រៀលគត់) និងជំពូក៦៥(ឧបត្ថម្ភធន និងជំនួយសង្គម) ចំនួន២០៩ ៤០០ ០០០រៀល(ពីររយប្រាំបួនលានបួនរយពាន់រៀលគត់) មកជំពូក៦២(សេវាខាងក្រៅផ្សេងៗ) ជូនក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់សោហ៊ុយបេសកកម្ម និងស្នាក់នៅក្នុងប្រទេសឆ្នាំ២០១០ ២០១១ និង២០១២។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៧៨៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងលើការនាំចូលត្បូងពេជ្រមិនទាន់កែច្នៃ

# និង

# ការនាំចេញត្បូងពេជ្រដែលបានកែច្នៃរួច ក្នុងការអនុវត្តន៍គម្រោងចេញវិញ្ញាបនបត្រគីមប៉រលី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦/៩៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីជូនដំណឹងលេខ ធ៩.០៩.៦០១ សជណ ស្តីពីការបញ្ឈប់ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុ និងត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ របស់ធនាគារជាតិ នៃកម្ពុជា។
- បានឃើញប្រកាសលេខ ២២៨ MOC / SM 2009 ស្តីពីការគ្រប់គ្រងអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ របស់ក្រសួងពាណិជ្ជកម្ម។
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងជំរុញឲ្យមានការវិនិយោគលើវិស័យត្បូងពេជ្រ និងបង្ការការនាំចូល និងការនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ ដែលមានទំនាស់មកព្រះរាជាណាចក្រកម្ពុជា ព្រមទាំងចូលរួមចំណែកអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីវិធាន លក្ខខណ្ឌ និងនីតិវិធីក្នុងការចេញវិញ្ញាបនបត្រសម្រាប់ការប្រកបអាជីវកម្មនាំចូល និងនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះប្រតិបត្តិការរបស់ពាណិជ្ជករ ដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងការនាំចូល ការនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខណ្ឌនៃប្រទេសដែលអនុវត្តគម្រោងគឹមប៉រលីប្រូសេស។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ ៖

-ត្បូងពេជ្រមានទំនាស់ សំដៅដល់ត្បូងពេជ្រមិនទាន់កែច្នៃ ដែលត្រូវបានប្រើប្រាស់ដោយពួកឧទ្ទាម ឬក្រុមសម្ព័ន្ធមិត្តរបស់ពួកគេ ដើម្បីផ្តល់ហិរញ្ញវត្ថុដល់ជម្លោះនានាសំដៅបំផ្លាញរដ្ឋាភិបាលនៃប្រទេសមួយទៀត។

-គីមប័រលីប្រូសេស សំដៅដល់ដំណើរការនៃការគ្រប់គ្រងមួយដែលមានការចូលរួមពីបណ្តាប្រទេសដែលធ្វើការនាំចូល និងនាំចេញត្បូងពេជ្រដែលមិនមានការពាក់ព័ន្ធនឹងត្បូងពេជ្រមានទំនាស់។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងផ្តល់ការបញ្ជាក់លើវិញ្ញាបនបត្រសម្រាប់ការនាំចូល ការនាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច ក្រោមការអនុវត្តន៍គម្រោងគីមប័រលីប្រូសេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## វិធានការគ្រប់គ្រងការនាំចូល និងការនាំចេញ

**មាត្រា ៦.-**

បុគ្គលដែលប្រកបអាជីវកម្មនាំចូល នាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានវិញ្ញាបនបត្រនាំចូល និងនាំចេញ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

លក្ខខណ្ឌ និងនីតិវិធីនៃការចេញវិញ្ញាបនបត្រនាំចូល នាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច ត្រូវកំណត់ដោយប្រកាសដោយឡែក ឬរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា ៧.-**

បុគ្គលដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រនាំចូល នាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច ត្រូវបង់កម្រៃសេវា ។

កម្រៃសេវាវិញ្ញាបនបត្រនាំចូល នាំចេញត្បូងពេជ្រមិនទាន់កែច្នៃ និងកែច្នៃរួច ត្រូវកំណត់ដោយប្រកាសរួម រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៨.-**

បុគ្គលដែលធ្វើអាជីវកម្មលើការកែច្នៃត្បូងពេជ្រ និងការនាំចូល នាំចេញ ក្រោមការអនុវត្តន៍គម្រោងគីមប៉រលី ត្រូវមកបំពេញបែបបទតាមបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ស្របតាមលក្ខខណ្ឌ និងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :.១៧៥..អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១**: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន១ ០០០ ០០០ ០០០រៀល(មួយពាន់លានរៀលគត់) ពីជំពូក ០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូកជំពូក ៦០ (ការទិញ) ចំនួន ៣៦២ ០០០ ០០០រៀល ជំពូក ៦១(សេវាខាងក្រៅ) ចំនួន៤០ ០០០ ០០០រៀល និងជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន៥៩៨ ០០០ ០០០រៀល របស់ក្រសួងទេសចរណ៍ (គណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា) សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១២។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយទ្រទ្រង់ដំណើរការការងាររបស់គណៈកម្មាធិការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា(គ.អ.ឆ.ក) នៅឆ្នាំ២០១២។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ ៩/៧ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
